រដ្ឋសភា
ចូល លេខ ........ ថ្ងៃទី ........ ម៉ោង ........ បញ្ជូនទៅ ........

# ព្រះរាជក្រម

នស/រកម/១២១៧/០៤០

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៥/០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើធម្មនុញ្ញនៃមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ នាសម័យប្រជុំពេញអង្គលើកទី១១ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើធម្មនុញ្ញ
# នៃមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី

**មាត្រា ១.-**

អនុម័តយល់ព្រមលើធម្មនុញ្ញនៃមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី ដែលត្រូវបានចុះហត្ថលេខា នៅរាជធានីបាងកកនៃព្រះរាជាណាចក្រថៃ នាថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៥ ហើយដែល មានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តធម្មនុញ្ញនេះ ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ថ្ងៃ សៅរ៍ ៦រោច ខែ មិគសិរ ឆ្នាំរកា ព.ស. ២៥៦១
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៩ ខែ ធ្នូ គ.ស. ២០១៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស.រកម.១២១៧.០១៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជា**
**អនុប្រធានប្រចាំការនៃគណៈកម្មាធិការជាតិ**
**គ្រប់គ្រងគ្រោះមហន្តរាយ**
**ហត្ថលេខា**
**ញឹម វណ្ណដា**

**លេខ:១១៨១ ស.ណ**
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
ថ្ងៃអង្គារ០៩រោច ខែមិគសិរ ឆ្នាំរកា ឆព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ,ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**



**សយ សុខា**